**LOWELL PUBLIC SCHOOLS**
Henry J. Mroz ការិយាល័យរដ្ឋបាលកណ្ដាល
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 5 ខែកុម្ភៈឆ្នាំ 2021

ជូនចំពោះសិស្សានុសិស្ស ក្រុមគ្រួសារ និងបុគ្គលិក Lowell Public Schools ជាទីគោរពរាប់អាន

ខ្ញុំសង្ឃឹមថាលិខិតនេះនឹងបានទៅដល់ដៃអ្នកយ៉ាងសុវត្ថិភាព។ ខ្ញុំមានក្តីសោមនស្សរីករាយសូមធ្វើការរាយការណ៍ថា និន្នាការចុងក្រោយបំផុតនៃទិន្នន័យជំងឺ COVID-19 នៅក្នុង Lowell នេះ បង្ហាញថាយើងអាចសម្រេចគោលដៅ នៃការបញ្ជូនក្រុមសិស្សដំបូងរបស់យើងត្រឡប់ទៅកាន់ការបង្រៀនដោយផ្ទាល់វិញបន្ទាប់ពីវិស្សមកាលខែកុម្ភៈនេះ។

អាស្រ័យហេតុនេះ យើងកំពុងរៀបចំផែនការដើម្បីឲ្យសិស្សទាំងអស់នោះនៅក្នុងកម្មវិធីអប់រំពិសេសដាច់ដោយឡែកសំខាន់ ដែលបានចូលរួមក្នុងគំរូសិក្សាដោយផ្ទាល់របស់យើងកាលពីមុនធ្វើការត្រឡប់មកអគារសាលាវិញចាប់ផ្តើមពីថ្ងៃចន្ទទី 22 ខែកុម្ភៈនេះតទៅ។

ដូចគ្នានេះដែរ យើងកំពុងស្ថិតក្នុងដំណើរការដើម្បីបញ្ជូនក្រុមសិស្សទីពីររបស់យើងឲ្យត្រឡប់ មកសិក្សាដោយផ្ទាល់វិញនៅថ្ងៃចន្ទទី 1 ខែមិនាផងដែរ - សិស្សទាំងអស់នោះ ដែលមិនស្ថិតនៅក្នុងកម្មវិធីអប់រំពិសេស ដាច់ដោយឡែកសំខាន់ ប៉ុន្តែកាលពីមុនបានទទួលសេវាដោយផ្ទាល់ក្នុងឆ្នាំសិក្សានេះ ជាផ្នែកមួយនៃផែនការដើម អំពីការបើកសាលារៀនឡើងវិញរបស់យើង។

រៀងរាល់ថ្ងៃព្រហស្បតិ៍ Commonwealth បញ្ចេញតារាងទិន្នន័យជំងឺ COVID-19 តាមសហគមន៍របស់ខ្លួន។ របាយការណ៍ សប្តាហ៍នេះ បង្ហាញពីអត្រាជំងឺ COVID-19 នៅក្នុង Lowell ដែលកំពុងបន្តមានភាពប្រសើរឡើង។ ចំនួនមធ្យម នៃករណីប្រចាំថ្ងៃនៅក្នុងប្រជាជន 100,000 នាក់ឥឡូវនេះគឺ 63.2 ថយចុះពីអត្រា 72.5 កាលពីសប្តាហ៍មុន 87.0 កាលពីពីរសប្តាហ៍មុន និងទាបជាងខ្លាំងបើធៀបនឹងអត្រាករណីប្រចាំថ្ងៃជាមធ្យម 134.4 កាលពីពាក់កណ្ដាលខែធ្នូ។ ទន្ទឹមនឹងនេះ "អត្រាវិជ្ជមានគិតជាភាគរយ" (ភាគរយនៃការធ្វើតេស្តដែលចេញលទ្ធផលវិជ្ជមាននៅក្នុង Lowell) ឥឡូវនេះគឺ 7.10 ថយចុះពី 8.37 កាលពីសប្តាហ៍មុន 10.15 កាលពីពីរសប្តាហ៍មុន និងទាបជាងខ្លាំងបើធៀបនឹង 12.33 កាលពីពាក់កណ្ដាល ខែធ្នូ។

គ្រួសាររបស់សិស្សដែលត្រូវត្រឡប់មកទទួលការបង្រៀនដោយផ្ទាល់នៅថ្ងៃទី 22 ខែកុម្ភៈ ឬថ្ងៃទី 1 ខែមីនា នឹងទទួលបាន ព័ត៌មានបន្ថែមពីសាលារៀនរបស់ពួកគេ។ យើងក៏នឹងធ្វើការទាក់ទងនៅសប្តាហ៍ក្រោយជាមួយការចែករំលែកព័ត៌មានពី មណ្ឌលដែលផ្តល់ជូនព័ត៌មានបន្ថែមអំពីមធ្យោបាយធ្វើដំណើរ សុវត្ថិភាពជំងឺ COVID-19 និងការប្រើប្រាស់ការធ្វើតេស្តជាពូល ដែលឧបត្ថម្ភដោយរដ្ឋសម្រាប់ជំងឺ COVID-19។

នៅខណៈពេលនេះ បើសិនជាកូនរបស់អ្នកមិនបានចូលរួមដោយផ្ទាល់នៅពេលណាមួយក្នុងឆ្នាំសិក្សានេះទេ សូមចំណាយពេល ពីរបីនាទី និងបំពេញការស្ទង់មតិនេះ ដែលធ្វើការស្ទាបស្ទង់ពីចំណាប់អារម្មណ៍របស់អ្នក បើសិនជាមាន ដើម្បីឲ្យកូនរបស់អ្នក ចូលរួមក្នុងការសិក្សាដោយផ្ទាល់នៅពេលក្រោយក្នុងឆ្នាំសិក្សានេះ។ ថ្ងៃទី 1 ខែមេសានៅតែជាកាលបរិច្ឆេទគោលដៅរបស់យើង ដើម្បីពង្រីកការសិក្សាដោយផ្ទាល់សម្រាប់សិស្សបន្ថែមទៀត លើសពីសិស្សដែលត្រូវបានកំណត់ឲ្យសិក្សាដោយផ្ទាល់ កាលពីដើមឆ្នាំសិក្សានេះ។

យើងសូមថ្លែងអំណរគុណសម្រាប់ការសហការ និងការបត់បែនរបស់អ្នកឆ្លងកាត់វិបត្តិសុខភាព ដែលមិនធ្លាប់មានពីមុនមកនេះ និងទន្ទឹងរង់ចាំស្វាគមន៍សិស្សានុសិស្សមកកាន់អគារសាលារបស់យើង នាពេលអនាគតដ៏ខ្លីខាងមុខនេះ។

ដោយក្តីស្មោះស្ម័គ្រ

Dr. Joel D. Boyd
នាយកសាលាប្រចាំមណ្ឌល